**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : 309 PEAC.អក

## សេចក្តីជូនដំណឹង
## ស្តីពី

ការអញ្ជើញចូលរួមពិគ្រោះថ្លៃលើ ឈ្នួលពលកម្មពង្រីកបណ្តាញអគ្គិសនី
ដើម្បីកាត់រំលែកបន្ទុក ប.ត ២០០ ,ប.ត ២០៧, ប.ត ២៨៩ នៅសង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ
និង ដើម្បីកាត់រំលែកបន្ទុក S426 នៅភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ
ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/ សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល )ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា:អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការងារលើ ឈ្នួលពលកម្មពង្រីកបណ្តាញអគ្គិសនីដើម្បីកាត់រំលែកបន្ទុក ប.ត ២០០ ,ប.ត ២០៧, ប.ត ២៨៩ នៅសង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញនិង ដើម្បីកាត់រំលែកបន្ទុក S426 នៅភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាស័យដ្ឋាន : ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ : 023 67 66 007 និង Website : www.edc.com.kh) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៥ វេលាម៉ោង ១១ :០០ នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៥ : ០០ នាទី ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៥ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារពិគ្រោះថ្លៃ និង សាកសួរពត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី 02 ខែ 04 ឆ្នាំ ២០១៥
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឆឹង_អ៊ីង**

ចម្លងជូន :
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ